**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ:៤៨៦
ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០០០
**សាលដីកា**
លេខ:១៧៩
ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ............ ជាប្រធាន
២-លោក ............... ជាចៅក្រមរបាយការណ៍
៣-លោក ................ ជាចៅក្រម
៤-លោក ................ ជាចៅក្រម
៥-លោក .................. ជាចៅក្រម

**ក្រឡាបញ្ជី**

-លោក ...............

**តំណាងមហាអយ្យការ**

-លោក ............ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៨៤(ធ) ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៥១៤ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍រាជធានី

ដើមចោទឈ្មោះ សស(ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ មានទីលំនៅសព្វថ្ងៃ ភូមិល្វាកោង ឃុំកំពង់ប្រាំង ស្រុកពារាំង ខេត្តព្រៃវែង ។ ឪពុកឈ្មោះសុក អ៊ុន(ស) ម្តាយឈ្មោះង៉ែត លីវ(រ) ប្តីឈ្មោះយ៉ន ម៉ុត មាន កូន០៣នាក់ ។

មានមេធាវី លោក ........ ។

ចុងចម្លើយឈ្មោះ ងសាវ (ជាចុងបណ្តឹងសាទុក្ខ) គេទស្រី អាយុ២៧ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ មានទីលំនៅសព្វថ្ងៃ ភូមិល្វាកោង ឃុំកំពង់ប្រាំង ស្រុកពារាំង ខេត្តព្រៃវែង ។ ឪពុកឈ្មោះង៉ែត ឡាច (ស) ម្តាយឈ្មោះ សឿ យ៉េង (រ) ប្តីឈ្មោះធូ ហ៊ានមានកូន០១នាក់ ។

មានមេធាវី អ្នកស្រី ......... ។

**កម្មវត្ថុបណ្តឹង :** ប្តឹងទាមទារដីភូមិ

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤៨៦ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០០ របស់តុលាការកំពូល ។

បានឃើញបណ្តឹងសាទុក្ខលេខ៣៤០ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០០ របស់ឈ្មោះសស ដប្តឹង មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៨៤(ធ) ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

ប្តឹងមិនសុខចិត្តនឹងសាលដីការ ឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី៣០-០៩-១៩៩៨ របស់ឈ្មោះ សស ប្តឹងពីឈ្មោះ ងសាវ បានរំលោភយកដីភូមិមួយកន្លែងទំហំ១៥អា ២០សង់ទីអា ២៦៣មីលីអា ពីខ្លួនដោយដីនេះកន្លងមក ឈ្មោះធូ យូ បានរស់នៅជាបណ្តោះអាសន្ន តែឥឡូវគាត់បានប្រគល់ដីនេះ មកឱ្យខ្លួនវិញ កាលពីថ្ងៃទី ១៨-០៥-១៩៩៧ ដោយមានសាក្សីដឹងឮពិតប្រាកដ និងមានហត្ថលេខារបស់ភូមិឃុំទៀតផង ។

តាមចម្លើយរបស់ឈ្មោះងសាវ បានឆ្លើយថា ខ្លួនបានថែរក្សាម្តាយមីង និងពូធូ យូតាំង ពីឆ្នាំ ១៩៨៤ ដល់ឆ្នាំ១៩៨៩ ទើបម្តាយមីងស្លាប់ ។ ក្រោយពេលម្តាយមីងស្លាប់ ខ្លួនក៏បានរៀបការនៅឆ្នាំ ១៩៩៧ ហើយ ពូ ធូយូ ក៏មករស់នៅជាមួយខ្លួន ដោយធ្វើកិច្ចសន្យាចិញ្ចឹមគាត់មួយជីវិត លុះដល់ឆ្នាំ ១៩៩៨ ពូធូយូ ក៏ស្លាប់ ខ្លួនក៏យកដីនោះលក់ដើម្បីយកប្រាក់ធ្វើបុណ្យសពគាត់ តែត្រូវឈ្មោះសុកសុនឃាត់ថា ដីនោះជាកម្មសិទ្ធិរបស់គេ តែតាមពិតដីនោះជាកម្មសិទ្ធិរបស់ពូ ធូយូ ទេ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៤៤ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩ របស់តុលាការ ខេត្តព្រៃវែង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះសស ចុះថ្ងៃទី៣០-៩-១៩៩៨មាន លក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលស្គាល់លិខិតប្រគល់ដីលំនៅដ្ឋានចុះថ្ងៃទី១៨-០៥-១៩៩៧ រវាងឈ្មោះ ធូ យូ និងឈ្មោះសស ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣-បដិសេធលិខិតផ្ទេរមត៌ក ចុះថ្ងៃទី២៦-០៨-១៩៩៨ រវាងឈ្មោះធូ យូ និងឈ្មោះ ងសាវ ចោលជាអសារបង់ ។

៤-ប្រគល់សិទ្ធិជាកម្មសិទ្ធិឱ្យទៅឈ្មោះសស លើដីលំនៅដ្ឋានស្ថិតនៅក្នុងភូមិល្វា កោង ឃុំកំពង់ប្រាំង ស្រុកពារាំង ខេត្តព្រៃវែង ដែលមានទំហំ១៥អា ២០សង្ទីអា ២៦៣មីលីអា មានព្រំប្រទល់ខាងជើង ទល់ដី ចាន់ គន់ ខាងត្បូងទល់ដី រ៉េត គ្រី ខាងលិចទល់ដីចំណីទន្លេ ខាងកើតទល់ ថ្នល់ ចាប់ពីថ្ងៃសាលក្រមនេះ ប្រកាសជាស្ថាពរ ។

៥-បង្គាប់ឱ្យឈ្មោះសស ចេញប្រាក់ចំនួន៥០០.០០០៛(ហាសិបម៉ឺនរៀល)ឱ្យទៅ ចុងចម្លើយឈ្មោះង៉ែត សារ៉េត ទុកធ្វើបុណ្យជូនសពតាធូ យូ នៅពេលសាលក្រមនេះចូលជាស្ថាពរ។

សុំលើសលើកចោល ។

៦-បង្គាប់ឱ្យចុងចម្លើយឈ្មោះង៉ែត សារ៉េត បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ១.៨០០៛ វង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ វង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០៛ សរុប៧.០០០៛ ។ ប្រាក់នេះដើមចោទបានបង់ទុករួចហើយ កាលបើហួសការប្តឹងឧទ្ធរណ៍ឱ្យឈ្មោះង៉ែតសារ៉េត ប្រគល់ប្រាក់ ៧.០០០៛ ទៅឱ្យដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រ១%លើតម្លៃដីទំនាស់នេះ ។ ប្រាក់នេះត្រូវដាក់ចូលថវិការដ្ឋ៨០% និងវង្វាន់ក្រឡបញ្ជីទូទាំងប្រទេស២០% ។

៧-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូភាគី ។ បើភាគីណាមិនសុខចិត្ត មានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩ របស់ឈ្មោះង៉ែត សារ៉េត ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៤៤ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩ របស់តុលាការខេត្តព្រៃវែង ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៨៤(ធ)ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២ ឧសភា១៩៩៩ របស់ឈ្មោះង៉ែត សារ៉េត ជាចុងចម្លើយ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមលេខ៤៤ ចុះថ្ងៃទី១២ ឧសភា ១៩៩៩ របស់តុលាការខេត្តព្រៃវែង ចោលជាអសារបង់ ។

៣-បដិសេធលិខិតប្រគល់ដីលំនៅដ្ឋាន ចុះថ្ងៃទី១៨ ឧសភា ១៩៩៧ ដែលក្នុងនោះឈ្មោះ ធូ យូ បានប្រគល់ដីលំនៅដ្ឋានឱ្យឈ្មោះ សស ចោលជាអសារបង់ ។

- ប្រគល់ដីលំនៅដ្ឋានដែលជាដីរបស់សពលោកតា ធូ យូ ស្ថិតនៅភូមិ ល្វាតោងឃុំកំពង់ប្រាំង ស្រុកពារាំងខេត្តព្រៃវែងឱ្យទៅឈ្មោះង៉ែត សារ៉េត កាន់កាប់ជាកម្មសិទ្ធិ កាលណាសាលដីកានេះចូលជាស្ថាពរ ។

- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍សរុប១៣.០០០៛ និងបង្គាប់ឱ្យឈ្មោះ សស បង់ពន្ធសមាមាត្រចំនួន១% នៃដីទំនាស់ ។

- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣៤០ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០០ របស់ឈ្មោះសសប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៨៤(ធ) ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០១ របស់ឈ្មោះសស ។

បាឃើញសារណាឆ្លើយតប ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០១ របស់ឈ្មោះ ង៉ែត សារ៉េត។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ចុះ ។

បានស្តាប់ក្រឡាបញ្ជីអានសារណារបស់ឈ្មោះសស នាពេលជំនុំជំរះ ។

បានស្តាប់ចម្លើយរបស់ឈ្មោះង៉ែត សារ៉េត នាពេលសវនាការថា : ការលើកឡើងក្នុងសារណារបស់ដើមចោទមិនត្រឹមត្រូវទេ ដីនេះជាកម្មសិទ្ធិរបស់ខ្លួន មានប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ ដីនេះតាធូ យូ ប្រគល់ឱ្យខ្លួនទាំងអស់កន្លងមកតាសុកសុន បានយកប័ណ្ណកម្មសិទ្ធិដីខ្លួនទៅ តែលេខមានអាដ្ឋាធរបញ្ជាក់ក្នុងសំណុំរឿងស្រាប់ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកប៊ិច វិច្ឆិកា មេធាវីការពារឱ្យដើមចោទនាពេលសវនាការថា : ដីនេះ ជាកម្មសិទ្ធិតា សស តាធូ យូ បានសុំខ្ចីដីពីតា សស នៅបណ្តោះអាសន្នទេ ក្រោយមក បែរជាតាធូ យូ យកប្រគល់ឱ្យងសារ ទៅវិញ ប័ណ្ណកម្មសិទ្ធិតាសសធ្វើឡើងត្រឹមត្រូវ ងសារថា ដីនេះតា ធូ យូ ប្រគល់ឱ្យមិនត្រឹមត្រូវទេ ពីព្រោះ ពេលធ្វើលិខិតប្រគល់ដីនោះតា ធូ យូ មានស្មារតីមិនប្រក្រតី ។ សាលាឧទ្ធរណ៍យល់ឃើញមិនត្រឹមត្រូវទេ ព្រោះឥតមានប័ណ្ណកម្មសិទ្ធិដើមផង មានតែប័ណ្ណកម្មសិទ្ធិលេខ១៥៦ ប៉ុណ្ណោះ ឥតមានប័ណ្ណលេខ១៥៥ទេ ។

សុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់អ្នកស្រី ......... មេធាវីការពារឱ្យចុងចម្លើយនៅពេលជំនុំជំរះ ថា: ការលើកឡើងរបស់មេធាវីដើមចោទ មិនត្រឹមត្រូវទេ ដីនេះតាធូ យូ នៅតាំងពីឆ្នាំ១៩៧៩ រហូត មកបានធ្វើប័ណ្ណសំគាល់កម្មសិទ្ធិហើយ ក្រោយមកបានប្រគល់ដីនេះឱ្យម៉ែត សារ៉េត ត្រឹមត្រូវតាមច្បាប់រួចហើយ ដើមចោទបានលួងយកប័ណ្ណកម្មសិទ្ធិពីកូនក្តីខ្លួនទៅ កែលេខប័ណ្ណពី១៥៥ ទៅលេខ១៥៦កូនក្តីខ្លួនមិនទាន់ប្តឹងពីបទព្រហ្មទណ្ឌផង ។ កូនក្តីខ្លួនថែរក្សាតាធូ យូ រហូតដល់គាត់ស្លាប់ ហេតុនេះសមទទួលមរតកមែនហើយ ។

សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការតទៅ ។

ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សារណារបស់ដើមចោទ ចម្លើយរបស់ចុងចម្លើយ និងសេចក្តី សន្និដ្ឋានការពាររបស់មេធាវីនៃគូភាគី .

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

<u>**តុលាការកំពូល**</u>

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣៤០ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០០ របស់លោក

សស ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលលោកសស និងមេធាវីរបស់លោកលើកឡើងនៅក្នុងសារណា ក៏ដូចជានៅពេលសវនាការនេះដែរ ដែលថា ដីទំនាស់នេះលោក ធូ យូ បានប្រគល់ឱ្យលោកសស តាមលិខិតប្រគល់ដីចុះថ្ងៃទី១៨-០៥-១៩៩៧ នោះគឺជាការពុំត្រឹមត្រូវទេ ពីព្រោះថាតាមលិខិតផ្ទេរកម្មសិទ្ធិ ដីចុះថ្ងៃទី១៣-៣-១៩៩៧ និងតាមលិខិតផ្ទេរមត៌កដីចុះថ្ងៃទី២៦-០៨-១៩៩៨ លោកធូ យូ ពិតជាបាន ផ្ទេរមត៌កដីនេះ ឱ្យទៅឈ្មោះងសាវ ហៅឡាច សាវ៉េត ប្រាកដមែន ។ ដូច្នេះតាមមាត្រា២០០ ចំណុច៣ នៃច្បាប់ភូមិបាលចាស់ លិខិតប្រគល់ដីចុះថ្ងៃទី១៨-០៥-១៩៩៧ មិនអាចយកមកអនុវត្តបានទេ ពីព្រោះដើមចោទពុំបានបំពេញកិច្ចថែទាំលោកធូ យូ មុនពេលលោកទទួលមរណភាព ហើយថែមទាំង បានកាប់បំផ្លាញផលដំណាំជាច្រើនលើដីទំនាស់ទៀតផង ។ ដោយឡែកចុងចម្លើយ ត្រូវមានសិទ្ធិទទួល ដីទំនាស់នេះតាមមាត្រា១៩៩ នៃច្បាប់ភូមិបាលចាស់ហើយ ។

- យល់ឃើញថា ការដែលមេធាវីដើមចោទលើកឡើងថា ដីទំនាស់នេះមានប័ណ្ណសំគាល់សិទ្ធិលេខ B10.០១៥៦ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះតាមរបាយការណ៍ ចុះថ្ងៃទី១០-០៨-១៩៩៨ របស់គណៈកម្មការដោះស្រាយបាតុភាពដីធ្លីស្រុកពារាំង និងតាមលិខិតលេខ១១/២០០០ ចុះថ្ងៃទី១៨-៥-២០០០ របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់និងភូមិបាល ស្រុកពារាំង បញ្ជាក់ច្បាស់លាស់ថា ដីរបស់ឈ្មោះធូ យូ និងនាងង៉ែតដើង(ដីទំនាស់) គឺពិតជាមានប័ណ្ណសំគាល់សិទ្ធិលេខB10.០១៥៥ និងមានចុះបញ្ជីអចលនវត្ថុត្រឹត្រូវ ចំណែកឯប័ណ្ណសំគាល់សិទ្ធិលេខB10.០១៥៦ គឺជាដីរបស់ឈ្មោះហោង ហុង និងនាងប៉ោង ញ៉ឹង និងបានចុះបញ្ជីអចលនវត្ថុត្រឹមត្រូវ ។

- យល់ឃើញថា ការដែលលោកសស លើកឡើងក្នុងសារណារបស់លោកថា លិខិតផ្ទេរ មរតកចុះថ្ងៃទី២៦-៨-១៩៩៨ ដែលផ្ទេរឱ្យឈ្មោះងសាវ ធ្វើក្រោយតា ធូ យូ ស្លាប់៤ថ្ងៃនោះគឺពុំត្រឹមត្រូវទេ ពីព្រោះតាមលិខិតបញ្ជាក់មរណភាពរបស់មេឃុំកំពង់ប្រាំងចុះថ្ងៃទី០៣-០៥-២០០១ បញ្ជាក់ ថា លោកធូ យូ ទទួលមរណភាពនៅថ្ងៃទី២២-៩-១៩៩៨ គឺទទួលមរណភាពក្រោយលិខិតផ្ទេរមតក ។

- យល់ឃើញថា ដីទំនាស់នេះ ឈ្មោះធូ យូ បានកាន់កាប់ និងរស់នៅតាំងពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៩៨ ទើបលោកទទួលមរណភាព រីឯឈ្មោះសស មិនដែលបានកាន់កាប់ និងរស់នៅលើ ដីទំនាស់នោះទេ ហើយតាមចម្លើយចុះថ្ងៃទី១៧-០៣-១៩៩៨ លោកសស ក៏បានឆ្លើយថា ដីទំនាស់ នេះជាកេរ្តិ៍របស់ម្តាយលោកមុនឆ្នាំ១៩៧៩ ហើយឈ្មោះធូ យូ បានសុំរស់នៅតាំងពីឆ្នាំ១៩៧៩ មក ។ ដូច្នេះលោក សស ពុំមានគុណសម្បត្តិអាចធ្វើជាម្ចាស់លើដីទំនាស់នេះបានទេ ។

- យល់ឃើញថា លោកសុកសុនបានធ្វើសារណារួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការ នេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៨៤(ធ) ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០០របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ។

**ហេតុដូច្នេះ**

**និច្ឆ័យសេចក្តីចំពោះមុខចុងចម្លើយកំបាំងមុខដើមចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ៣៤០ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០០ របស់លោកសសទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៨៤(ធ) ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០០របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលលោកសស បានបង់គឺ :

-ពន្ធចុះបញ្ជីក្តី នឹងពន្ធហ្វីងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ បង្គាប់ឱ្យលោក សស បង់ពន្ធសមាមាត្រ១%លើតម្លៃដីទំនាស់ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣ ។